# ព្រះរាជក្រម

នស/រកម/១១១៩/០១៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្តីពី

# កិច្ចការពារអ្នកប្រើប្រាស់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះមានគោលបំណងធានាឱ្យមានកិច្ចការពារអ្នកប្រើប្រាស់និងចូលរួមលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។

**មាត្រា២ .-** គោលដៅ

ច្បាប់នេះមានគោលដៅកំណត់វិធាននិងយន្តការដើម្បីចូលរួមចំណែកបង្កើតបរិយាកាសនៃការធ្វើពាណិជ្ជកម្មដែលក្នុងនោះ៖

- សិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ
- ការធ្វើពាណិជ្ជកម្មនោះមានការប្រកួតប្រជែងដោយសុចរិត និង
- អ្នកប្រើប្រាស់និងពាណិជ្ជករធ្វើសកម្មភាពជាមួយគ្នាដោយមានទំនុកចិត្ត។

**មាត្រា៣ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលធ្វើធុរកិច្ច ទោះបីរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញក្តី រួមទាំងការលក់ទំនិញឬសេវាផ្សេងៗឬសិទ្ធិប្រត្យក្សលើអចលនទ្រព្យ ឱ្យអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

**មាត្រា៤ .-** និយមន័យ

១- **ការទទួលបាន** សំដៅដល់ការទទួលបានទំនិញនិងសិទ្ធិប្រត្យក្សលើអចលនទ្រព្យតាមរយៈអំណោយ ការទិញលក់ ការដោះដូរ ឬតាមការព្រមព្រៀងផ្សេងៗទៀត ព្រមទាំងការទទួលបានសេវាតាមរយៈការព្រមព្រៀងនានា។

២- **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការផ្សព្វផ្សាយជាសាធារណៈឬការផ្សព្វផ្សាយទៅកាន់ក្រុមណាមួយក្នុងចំណោមសាធារណជនទោះតាមទម្រង់ណាក៏ដោយ ក្នុងគោលបំណងជំរុញការផ្គត់ផ្គង់ទំនិញ ឬសេវា ឬការលក់ឬការផ្តល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

៣- **បញ្ញត្តិករមានសមត្ថកិច្ច** សំដៅដល់ក្រសួង ស្ថាប័នណាមួយដែលមានមុខងារនិងតួនាទីការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់អ្នកប្រើប្រាស់ក្រោមការទទួលខុសត្រូវរបស់ខ្លួន។

៤- **ធុរកិច្ច** សំដៅដល់សកម្មភាពដែល៖

- ទំនិញឬសេវាត្រូវបានទទួលឬផ្គត់ផ្គង់ ឬដែលសិទ្ធិប្រត្យក្សលើអចលនទ្រព្យ ត្រូវបានទទួលឬបោះបង់ ឬ
- បានធ្វើឡើងតាមវិធីដែលមានការរៀបចំនិងមានភាពច្បាស់លាស់ ឬ
- បុគ្គលធ្វើសកម្មភាពនោះមានគោលបំណងរកប្រាក់ចំណេញទោះបីជាសកម្មភាពដែលបានធ្វើដោយបុគ្គលនោះជាសកម្មភាពចម្បង ឬបន្ទាប់បន្សំ ឬមិនធ្វើជាប្រចាំក៏ដោយ។

៥- **អ្នកប្រើប្រាស់** សំដៅដល់ បុគ្គលដែលទទួលបានទំនិញឬសេវា៖

ក- ដែលជាធម្មតាយកទៅប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួន ក្នុងផ្ទះ ឬក្នុងគ្រួសារ និង

ខ- ក្នុងគោលបំណង៖

- មិនផ្គត់ផ្គង់បន្តក្នុងការធ្វើពាណិជ្ជកិច្ច ឬ

- មិនប្រើប្រាស់ក្នុងដំណើរការចង្វាក់ផលិតកម្មឬការផលិត ឬ
- មិនប្រើប្រាស់ទំនិញក្នុងសកម្មភាពពាណិជ្ជកម្ម ដូចជា ដើម្បីជួសជុលអគារឬយកទៅធ្វើជាវត្ថុតាំងភ្ជាប់លើអចលនទ្រព្យ។

៦- **សិទ្ធិអ្នកប្រើប្រាស់** សំដៅដល់៖

- សិទ្ធិទទួលបានព័ត៌មាននិងការអប់រំដើម្បីថ្លឹងថ្លែងនូវភាពខុសគ្នារវាងទំនិញឬសេវា និងដើម្បីការពារពីការក្លែងបន្លំនិងពីការបោកប្រាស់តាមការផ្សាយពាណិជ្ជកម្ម
- សិទ្ធិជ្រើសរើសទំនិញឬសេវាដែលមានការប្រកួតប្រជែងគ្នាអំពីថ្លៃនិងគុណភាព
- សិទ្ធិត្រូវបានដឹងឮអំពីកង្វល់និងទទួលការពិនិត្យដោះស្រាយពីបញ្ញត្តិករមានសមត្ថកិច្ចនិងរាជរដ្ឋាភិបាល
- សិទ្ធិទាមទារសំណងតាមច្បាប់នេះឬតាមច្បាប់ផ្សេង។

៧- **អំពើ** សំដៅដល់ការធ្វើ ការបដិសេធ ឬការមិនអើពើក្នុងការធ្វើសកម្មភាពណាមួយ រួមទាំងការគ្រប់គ្រងឬការដឹកនាំសកម្មភាពធុរកិច្ច។

៨- **ការលាតត្រដាងព័ត៌មាន** សំដៅដល់ការបង្ហាញព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវដល់សាធារណជន។

៩- **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់សកម្មភាពទិញលក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

១០- **ការប្រកួតប្រជែងដោយសុចរិត** សំដៅដល់ការប្រកួតប្រជែងឈរលើមូលដ្ឋានថ្លៃទាប គុណភាពល្អ និងសេវាល្អ ដោយផ្អែកលើគោលការណ៍និរន្តរភាពផ្នែកសេដ្ឋកិច្ចយូរអង្វែងនិងមិនបំពានអំណាចឬដំហរឧត្តមភាពលើទីផ្សារ។

១១- **ការអះអាងដោយបំភាន់** សំដៅដល់ការអះអាងមួយដែលបុគ្គលកំពុងធ្វើសកម្មភាពធុរកិច្ចណាមួយធ្វើឱ្យអ្នកប្រើប្រាស់ជឿថាអ្វីមួយពិត ប៉ុន្តែជាក់ស្តែងមិនមែនជាការពិត។

១២- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតឬរៀបចំឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ជាធរមាន ទោះបីដើម្បីរកប្រាក់ចំណេញឬមិនរកប្រាក់ចំណេញក្តី បានចុះបញ្ជីឬមិនបានចុះបញ្ជីក្តី។

១៣- **ការផ្សព្វផ្សាយព័ត៌មាន** សំដៅដល់ការធ្វើឱ្យដឹងដល់សាធារណជនទូទៅ រួមបញ្ចូលទាំង ការផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់បញ្ញត្តិករពាក់ព័ន្ធឬតាមមធ្យោបាយផ្សេងៗទៀតដែលសាធារណជនមានលទ្ធភាពអាចរកព័ត៌មានបានដោយសេរីនិងដោយគ្មានការរារាំង។

១៤- **សេវា** សំដៅដល់រាល់សិទ្ធិ អត្ថប្រយោជន៍ អាទិភាព ឬរាល់ការសម្រួលទាំងឡាយដែលត្រូវបានផ្តល់ឬបានឱ្យតាមប្រភេទនៃកិច្ចសន្យា មានជាអាទិ៍ដូចខាងក្រោម លើកលែងសេវាហិរញ្ញវត្ថុមិនមែនធនាគារ៖

ក- កិច្ចសន្យាទាក់ទងដល់៖

- ការបំពេញការងារទោះបីមានឬគ្មានការផ្គត់ផ្គង់ទំនិញក៏ដោយ ឬ
- ការផ្តល់ភាពងាយស្រួលឬការពេញចិត្តលើភាពងាយស្រួលរួមមាន ការស្នាក់នៅ ការលំហែ ការថែទាំមនុស្ស សត្វ ឬវត្ថុផ្សេងៗ ការកម្សាន្ត(លើកលែងល្បែងពាណិជ្ជកម្ម) ចំណត ឬ
- ការផ្តល់សិទ្ធិ អត្ថប្រយោជន៍ ឬផ្តល់អាទិភាព ដើម្បីទទួលបានប្រាក់កម្រៃ។

ខ- កិច្ចសន្យារវាងអ្នកផ្តល់សេវាហិរញ្ញវត្ថុជាមួយនឹងអតិថិជនរបស់ខ្លួន។

១៥- **ការផ្គត់ផ្គង់** សំដៅដល់៖

- ការផ្គត់ផ្គង់ទំនិញតាមរយៈការផ្តល់ជាអំណោយ ការលក់ ការដោះដូរ ការជួល ឬការទិញដោយបង់ម្លស់ជាដើម និង
- ការផ្តល់សេវា។

១៦- **ការផ្គត់ផ្គង់ច្រើនលើក** សំដៅដល់៖

- ការផ្គត់ផ្គង់ច្រើនលើកដែលមានលក្ខណៈជាអចិន្ត្រៃយ៍នូវទំនិញតាមរយៈការផ្តល់ជាអំណោយ ការលក់ ការដោះដូរ ការជួល ឬការទិញដោយបង់ម្លស់ និង
- ការផ្តល់សេវាច្រើនលើក។

១៧- **សេចក្តីបរិយាយពាណិជ្ជកម្ម** សំដៅដល់ការបង្ហាញឬការបរិយាយអំពីទំនិញ រួមមានបរិមាណឬទំហំ របៀបបង្កើតឬផលិត សារធាតុដែលប្រើប្រាស់សម្រាប់ផលិត ពេលវេលាផលិត ភាពសមតាមបំណង ភាពមាំ មុខងារ លក្ខណៈឬភាពត្រឹមត្រូវ និងចរិតលក្ខណៈនៃរូបរាងដែលជាប់នឹងទំនិញ។ សេចក្តីបរិយាយពាណិជ្ជកម្មមិនរាប់បញ្ចូលម៉ាកឬពាណិជ្ជនាមឡើយ។

១៨- **អំពើមិនសុចរិត** សំដៅដល់អំពើណាមួយរបស់បុគ្គលនៅក្នុងធុរកិច្ចដែលអាចបំភាន់ឬបោកបញ្ឆោតអ្នកប្រើប្រាស់ ទោះបីជាអំពើនោះធ្វើដោយចេតនាឬអចេតនា ក៏ដោយ៖

- ទង្វើឬអំណះអំណាងទាំងឡាយ ដូចជា ការផ្សាយពាណិជ្ជកម្ម ការជំរុញការលក់ និងអំណះអំណាងផ្សេងទៀត
- ការធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីថ្លៃ តម្លៃ ឬគុណភាពនៃទំនិញឬសេវា។ បុគ្គលក្នុងធុរកិច្ចមិនអាចពឹងផ្អែកទៅលើការបោះពុម្ពអក្សរនិងស្លាកសញ្ញាតូចៗពិបាកមើល និងការអះអាងការពារខ្លួនដែលមានលក្ខណៈធ្វើឱ្យមានភាពភាន់ច្រឡំ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ
- ការមិនបង្ហាញដល់អ្នកប្រើប្រាស់នូវការសន្យា ការរំពឹងទុក និងព័ត៌មានដែលពាក់ព័ន្ធ
- ទាញអត្ថប្រយោជន៍ពីអ្នកប្រើប្រាស់ ប្រសិនបើអ្នកផ្គត់ផ្គង់ដឹងថាអ្នកប្រើប្រាស់មិនស្ថិតក្នុងជំហរអាចការពារផលប្រយោជន៍របស់ខ្លួនបានឬមិនមានសមត្ថភាពយល់ដឹងពីទំនិញឬសេវា ដូចជា ចរិតលក្ខណៈ ប្រភេទ ភាសា អានុភាពនៃប្រតិបត្តិការឬបញ្ហានានាដែលទាក់ទងនឹងប្រតិបត្តិការនោះ ឬ
- អំពើផ្សេងៗទៀតដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .-** គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់

ត្រូវបានបង្កើតគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដោយមានអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់របស់ក្រសួងពាណិជ្ជកម្ម ជាសេនាធិការ ដើម្បីបំពេញភារកិច្ចនានាពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ ស្របតាមបញ្ញត្តិនៃច្បាប់នេះ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## សមាគមអ្នកប្រើប្រាស់

**មាត្រា៦ .-** ការបង្កើតសមាគមអ្នកប្រើប្រាស់

អ្នកប្រើប្រាស់តាមវិស័យនីមួយៗមានសិទ្ធិបង្កើតសមាគមរបស់ខ្លួនដោយត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

**មាត្រា៧ .-** សមាគមអ្នកប្រើប្រាស់

សមាគមអ្នកប្រើប្រាស់តាមវិស័យណាមួយ ត្រូវមានការអនុញ្ញាតពីក្រសួងឬស្ថាប័នដែលមានតួនាទីនិងភារកិច្ចគ្រប់ដណ្តប់លើវិស័យរបស់ខ្លួនជាមុនសិន។

បន្ទាប់ពីបានបង្កើតនិងចុះបញ្ជីសមាគមនៅក្រសួងមហាផ្ទៃនិងទទួលបានការអនុញ្ញាតពីបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធរួចហើយ សមាគមនោះត្រូវតម្កល់ឯកសារចុះបញ្ជីនិងលិខិតអនុញ្ញាតខាងលើ នៅគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា៨ .-** តួនាទីនិងភារកិច្ចរបស់សមាគមអ្នកប្រើប្រាស់

សមាគមអ្នកប្រើប្រាស់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាឯករាជ្យជូនអ្នកប្រើប្រាស់និងសម្របសម្រួលបញ្ហាទាក់ទងនឹងអ្នកប្រើប្រាស់
- ធ្វើជាអ្នកតំណាងចំពោះមុខគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ឬចំពោះមុខតុលាការជំនួសអ្នកប្រើប្រាស់ណាមួយឬក្រុមអ្នកប្រើប្រាស់ ដែលសិទ្ធិនិងផលប្រយោជន៍របស់ពួកគាត់ត្រូវបានបំពាន
- តំណាងទស្សនៈនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់នៅក្នុងវេទិកាសាធារណៈ ឬសារព័ត៌មាន
- ទទួលការប្រឹក្សាពីបញ្ញត្តិករមានសមត្ថកិច្ចណាមួយ អំពីបទប្បញ្ញត្តិស្តីពីបទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ ដែលចេញដោយបញ្ញត្តិករមានសមត្ថកិច្ចនោះ
- បង្កើតក្រុមការងារការពារអ្នកប្រើប្រាស់តាមវិស័យនីមួយៗ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ប្រគល់ជូន។

## ជំពូកទី៤
## អំពើមិនសុចរិតក្នុងធុរកិច្ច

**មាត្រា៩ .-** អំពើមិនសុចរិត

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតឡើយ។

អំពើមិនសុចរិត សំដៅដល់អំពើណាមួយរបស់បុគ្គលនៅក្នុងធុរកិច្ចដែលអាចបំភាន់ឬបោកបញ្ឆោតអ្នកប្រើប្រាស់ ទោះបីជាអំពើនោះធ្វើដោយចេតនាឬអចេតនា ក៏ដោយ៖

- ទង្វើឬអំណះអំណាងទាំងឡាយ ដូចជា ការផ្សាយពាណិជ្ជកម្ម ការជំរុញការលក់ និងអំណះអំណាងផ្សេងទៀត

- ការធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីថ្លៃ តម្លៃ ឬគុណភាពនៃទំនិញឬសេវា។ បុគ្គលក្នុងធុរកិច្ចមិនអាចពឹងផ្អែកទៅលើការបោះពុម្ពអក្សរនិងស្លាកសញ្ញាតូចៗពិបាកមើល និងការអះអាងការពារខ្លួនដែលមានលក្ខណៈធ្វើឱ្យមានភាពភាន់ច្រឡំ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ
- ការមិនបង្ហាញដល់អ្នកប្រើប្រាស់នូវការសន្យា ការរំពឹងទុក និងព័ត៌មានដែលពាក់ព័ន្ធ
- ការទាញអត្ថប្រយោជន៍ពីអ្នកប្រើប្រាស់ ប្រសិនបើអ្នកផ្គត់ផ្គង់ដឹងថាអ្នកប្រើប្រាស់មិនស្ថិតក្នុងជំហរអាចការពារផលប្រយោជន៍របស់ខ្លួនបានឬមិនមានសមត្ថភាពយល់ដឹងពីទំនិញ ឬសេវា ដូចជាចរិតលក្ខណៈ ប្រភេទ ភាសា អានុភាពនៃប្រតិបត្តិការ ឬបញ្ហានានាដែលទាក់ទងនឹងប្រតិបត្តិការនោះ ឬ
- អំពើផ្សេងៗទៀតដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា១០ .- អំពើមិនសុចរិតទាក់ទងនឹងទំនិញ**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈជាការបំភាន់ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ដំណើរការផលិត ចរិតលក្ខណៈ ភាពសមតាមបំណង បរិមាណ រង្វាស់រង្វាល់ ក្រិតខ្នាត ស្តង់ដា ឬគុណភាពនៃទំនិញឡើយ។

**មាត្រា១១ .- អំពើមិនសុចរិត *ទាក់ទងនឹងសេវា***

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈបំភាន់ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ស្តង់ដា ចរិតលក្ខណៈ ភាពសមតាមបំណង ទំហំឬគុណភាពនៃសេវាឡើយ។

**មាត្រា១២ .- ការអះអាងដោយបំភាន់**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវផ្គត់ផ្គង់ ជំរុញការផ្គត់ផ្គង់ ឬជំរុញការប្រើប្រាស់ទំនិញ ឬសេវា ដោយអះអាងដោយបំភាន់ណាមួយដូចខាងក្រោម៖

- ទំនិញនោះមានលក្ខណៈពិសេសដោយឡែកចំពោះប្រភេទ បទដ្ឋាន គុណភាព ចំណាត់ថ្នាក់ បរិមាណ សមាសធាតុ រចនាបថ ម៉ូដែល ឬទំនិញនោះមានប្រវត្តិពិសេស ឬទំនិញនោះមានការប្រើប្រាស់ពិសេសកន្លងមកហើយ
- សេវានោះមានលក្ខណៈពិសេសដោយឡែកចំពោះ ប្រភេទ បទដ្ឋាន គុណភាព ទំហំ ឬសេវានោះត្រូវបានផ្គត់ផ្គង់ដោយបុគ្គលពិសេសណាមួយ ឬដោយបុគ្គលណាមួយដែលមានមុខជំនាញ ឬមានលក្ខណសម្បត្តិពិសេសក្នុងការធ្វើពាណិជ្ជកម្ម
- បុគ្គលមានកេរ្តិ៍ឈ្មោះណាមួយបានឯកភាពទទួលទំនិញឬសេវានោះរួចហើយ
- ទំនិញនោះជាទំនិញថ្មី ឬជាទំនិញដែលត្រូវបានធ្វើឱ្យដូចថ្មី ឬជាទំនិញដែលបានផលិត បានបង្កើតឡើង បានកែច្នៃ នៅពេលវេលាពិសេសជាក់លាក់ណាមួយ
- ទំនិញឬសេវានោះមានការឧបត្ថម្ភគាំទ្រ មានការទទួលស្គាល់ មានការបញ្ជាក់ មានប្រសិទ្ធភាពសម្រាប់ការប្រើប្រាស់ មានវត្ថុរណប មានការប្រើប្រាស់ច្រើន ឬមានអត្ថប្រយោជន៍ច្រើន
- បុគ្គលណាមួយបានឧបត្ថម្ភគាំទ្រ បានទទួលស្គាល់ បានបញ្ជាក់ ឬមានសម្ព័ន្ធភាពជាមួយ
- ទំនិញឬសេវានោះមានការទទួលស្គាល់អំពីថ្លៃ
- ទំនិញឬសេវានោះមានតម្រូវការច្រើន

- ទំនិញឬសេវានោះមានរួមបញ្ចូលឬមិនរួមបញ្ចូលនូវការធានារ៉ាប់រង សំណងទូទាត់ ឬដំណោះស្រាយសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត
- ទំនិញមានប្រភពដើមមកពីទីកន្លែងណាមួយ។

ការអះអាងដោយបំភាន់ផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់តាមសំណើរបស់បញ្ញត្តិករមានសមត្ថកិច្ច។

## ជំពូកទី៥

## ការអនុវត្តមិនសុចរិត

**មាត្រា១៣ .-** ការហាមឃាត់ការលក់មិនសុចរិត

ការលក់ដែលធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំក្នុងការទិញទំនិញឬសេវាត្រូវហាមឃាត់។

**មាត្រា១៤ .-** ការសន្យាផ្តល់ជាអំណោយនិងរង្វាន់

រាល់បុគ្គលមិនត្រូវសន្យាផ្តល់ជាអំណោយ រង្វាន់ ឬវត្ថុឥតគិតថ្លៃដទៃទៀត ក្នុងចេតនាបោកប្រាស់ ឬភូតកុហកដល់អ្នកប្រើប្រាស់ពាក់ព័ន្ធនឹង៖

- ការផ្គត់ផ្គង់ទំនិញឬសេវា ឬ
- ការលក់ឬការផ្តល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

**មាត្រា១៥ .-** ការផ្សាយពាណិជ្ជកម្មជានុយ

១- រាល់បុគ្គលមិនត្រូវផ្សាយពាណិជ្ជកម្មដើម្បីផ្គត់ផ្គង់ទំនិញឬសេវាក្នុងថ្លៃជាក់លាក់ណាមួយដែលបុគ្គលនោះគ្មានបំណងផ្គត់ផ្គង់ឬគ្មានមូលដ្ឋានសមស្របដែលអាចជឿជាក់បានថាបុគ្គលនោះអាចផ្គត់ផ្គង់បានតាមថ្លៃដែលបានផ្សាយ។

២- រាល់បុគ្គលដែលបានផ្សាយពាណិជ្ជកម្មទំនិញឬសេវាដើម្បីផ្គត់ផ្គង់ក្នុងថ្លៃជាក់លាក់ណាមួយត្រូវតែផ្គត់ផ្គង់ទំនិញឬសេវានោះតាមថ្លៃដែលបានផ្សាយនោះក្នុងរយៈពេលកំណត់ណាមួយនិងបរិមាណសមរម្យ។

៣- ក្នុងករណីមានបណ្តឹងឬការតវ៉ាចំពោះបុគ្គលណាមួយ ពាក់ព័ន្ធនឹងការមិនបានផ្តល់ទំនិញ ឬសេវាទៅឱ្យអ្នកប្រើប្រាស់ តាមបញ្ញត្តិដែលមានចែងក្នុងមាត្រានេះ បុគ្គលនោះអាចការពារខ្លួនបាន ប្រសិនបើបុគ្គលនោះបង្ហាញថា៖

ក- បានផ្តល់ការផ្គត់ផ្គង់ឬឱ្យបុគ្គលផ្សេងទៀតដែលទទួលសិទ្ធិផ្គត់ផ្គង់ទំនិញឬសេវាដែលបានផ្សាយពាណិជ្ជកម្មដល់អ្នកប្រើប្រាស់ជំនួសគាត់ ក្នុងរយៈពេលកំណត់ណាមួយ ក្នុងបរិមាណកំណត់ណាមួយ និងក្នុងថ្លៃ ដូចដែលបានផ្សាយពាណិជ្ជកម្ម ហើយដែលការផ្គត់ផ្គង់នោះត្រូវបានយល់ព្រមពីអ្នកប្រើប្រាស់ផងដែរ។

ខ- បានផ្តល់ការផ្គត់ផ្គង់ភ្លាមៗឬឱ្យបុគ្គលផ្សេងទៀតដែលទទួលសិទ្ធិផ្គត់ផ្គង់ជំនួសគាត់ក្នុងអំឡុងពេលកំណត់មួយជូនដល់អ្នកប្រើប្រាស់នូវទំនិញឬសេវាដែលសមមូលទាំងបរិមាណ ទាំងថ្លៃ ដូចដែលបានផ្សាយពាណិជ្ជកម្ម ហើយដែលការផ្គត់ផ្គង់នោះត្រូវបានយល់ព្រមពីអ្នកប្រើប្រាស់ផងដែរ។

**មាត្រា១៦ .-** ការលក់អូសទាញដោយមិនសុចរិត

ការលក់អូសទាញដោយមិនសុចរិត សំដៅដល់ការលក់ទាក់ទាញឬជំរុញ អ្នកទិញណាម្នាក់ឱ្យទិញទំនិញ ឬសេវាដោយផ្អែកលើលក្ខខណ្ឌថា អ្នកទិញនោះនឹងទទួលបានប្រាក់រង្វាន់ ប្រាក់កម្រៃជើងសារ ឬ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

អត្ថប្រយោជន៍ដទៃទៀតជាថ្នូរនឹងការផ្ដល់ឈ្មោះអតិថិជនសក្ដានុពល ឬម្យ៉ាងទៀត ជួយដល់បុគ្គលនោះក្នុងការបញ្ចុះបញ្ចូលឬអូសទាញអ្នកទិញឬអ្នកប្រើប្រាស់ផ្សេងទៀតដើម្បីទទួលបានកម្រៃជើងសារឬការបញ្ចុះថ្លៃទំនិញឬបង្កើតនូវព្រឹត្តិការណ៍ផ្សេងទៀតអូសទាញអ្នកទិញផ្សេងទៀតឱ្យមកទិញទំនិញតាមការបញ្ចុះបញ្ចូលរបស់អ្នកប្រើប្រាស់ដំបូងមែន ហើយអតិថិជនសក្ដានុពលនោះពិតជាបានមកទិញទំនិញឬសេវាតាមការបញ្ចុះបញ្ចូលរបស់អ្នកទិញឬអ្នកប្រើប្រាស់ដំបូងមែន ប៉ុន្តែលក្ខខណ្ឌទាំងនោះមិនត្រូវបានបំពេញដោយអ្នកលក់។

**មាត្រា១៧ .- ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ**

មុនពេលផ្គត់ផ្គង់ទំនិញឬសេវា អ្នកផ្គត់ផ្គង់មិនត្រូវទាមទារឬទទួលយកនូវការទូទាត់ឬតម្លៃតបស្នងដទៃទៀត ក្នុងករណីដែលអ្នកផ្គត់ផ្គង់នោះ៖

- មិនមានបំណងផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ ឬ
- មានបំណងផ្គត់ផ្គង់ទំនិញឬសេវាដែលខុសពីទំនិញឬសេវាតាមការបញ្ជាទិញ ឬ
- មិនមានមូលហេតុសមហេតុផលដើម្បីបញ្ជាក់ថាអ្នកផ្គត់ផ្គង់នោះអាចនឹងផ្គត់ផ្គង់ទំនិញឬសេវាបានក្នុងរយៈពេលកំណត់ឬក្នុងរយៈពេលសមស្របតាមការបញ្ជាទិញ។

**មាត្រា១៨ .- ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន**

១- បុគ្គលណាមួយមិនត្រូវធ្វើការអះអាងដែលមិនពិតឬដែលបំភាន់ ទាក់ទងទៅនឹងការទទួលបានចំណេញ ហានិភ័យ ឬសារៈសំខាន់ផ្សេងៗទៀតក្នុងសកម្មភាពធុរកិច្ចណាមួយដែលបុគ្គលនោះបានអះអាងថាបុគ្គលផ្សេងទៀតអាចធ្វើសកម្មភាពធុរកិច្ចនោះបានពីទីលំនៅរបស់ខ្លួន។

២- បុគ្គលណាមួយមិនត្រូវធ្វើការអះអាងដែលមិនពិតឬដែលបំភាន់លើចំណុចសំខាន់ៗទាក់ទងនឹងការទទួលបានចំណេញ ហានិភ័យ ឬសារៈសំខាន់ដទៃទៀតនៃសកម្មភាពធុរកិច្ចណាមួយដែលបុគ្គលនោះអញ្ជើញបុគ្គលដទៃទៀតតាមរយៈការផ្សាយពាណិជ្ជកម្មឬតាមមធ្យោបាយផ្សេងទៀតឱ្យចូលរួមហើយដែលសកម្មភាពធុរកិច្ចនោះតម្រូវឱ្យមាន៖

ក- ការចូលរួមបំពេញការងារដោយបុគ្គលដទៃទៀត ឬ

ខ- ការវិនិយោគប្រាក់និងការចូលរួមបំពេញការងារដោយបុគ្គលដែលទាក់ទងនឹងការវិនិយោគនោះ។

**មាត្រា១៩ .- ការបង្ខិតបង្ខំដោយកម្លាំងនិងការគំរាមតាមផ្លូវចិត្ត**

បុគ្គលណាមួយមិនត្រូវបង្ខិតបង្ខំដោយកម្លាំងដោយការរំខានឬដោយការគំរាមតាមផ្លូវចិត្តទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវាឬការទូទាត់ប្រាក់សម្រាប់ទំនិញឬសេវាឡើយ។

**មាត្រា២០ .- គម្រោងលក់បែបពីរ៉ាមីដ**

បុគ្គលណាមួយមិនត្រូវជំរុញឬប្រតិបត្តិគម្រោងលក់បែបពីរ៉ាមីដឡើយ។

គម្រោងលក់បែបពីរ៉ាមីដ គឺជាគម្រោងដែល៖

១- ផ្ដល់ការផ្គត់ផ្គង់ទំនិញនិង/ឬសេវាដើម្បីទទួលបានប្រាក់រង្វាន់ឬតម្លៃតបស្នងមកវិញនិង

២- បង្កើតឱកាសលក់ទិញ ឱកាសវិនិយោគមួយដល់អ្នកចូលរួមជាច្រើនជាលក្ខណៈបុគ្គលឬតាមរយៈភ្នាក់ងារដែលមិនមែនជាការបង្កើតឱកាសលក់ទិញទំនិញឬសេវាពិតប្រាកដ និង

៣- គម្រោងនេះមានលក្ខណៈមិនសុចរិតចំពោះអ្នកចូលរួមជាច្រើន ពីព្រោះ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ប្រាក់រង្វាន់ឬតម្លៃតបស្នងរបស់អ្នកចូលរួមទាំងនោះគឺពឹងផ្អែកលើការជ្រើសរើសអ្នកចូលរួមបន្ថែម
- អ្នកចូលរួមថ្មីមិនអាចរកអ្នកចូលរួមបន្ថែមទៀតបាន។

**មាត្រា២១ .- ការលក់ទំនិញដែលមានភ្ជាប់សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិត**

បុគ្គលណាមួយមិនត្រូវលក់ទំនិញដែលមានភ្ជាប់សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិតឡើយ។

សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិត គឺជាសេចក្ដីបរិយាយដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញ ឬការជំរុញការផ្គត់ផ្គង់ទំនិញតាមគ្រប់មធ្យោបាយឬការប្រើប្រាស់ទំនិញដែលត្រូវបានចាត់ទុកថាមិនពិត។

មាត្រានេះអនុវត្តលើទំនិញទាំងឡាយដែលមានភ្ជាប់សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិតដោយៈ

- ដេរ សង្កត់ពុម្ពពីលើ បញ្ចូល ភ្ជាប់ ឬបិទពីលើទំនិញ ឬ
- បង្ហាញលើគម្រប លើស្លាក លើបំពង់ លើស្រោមសំបកវេចខ្ចប់ឬលើទំនិញ។

**មាត្រា២២ .- ការអនុវត្តមិនសុចរិតផ្សេងទៀត**

ការអនុវត្តមិនសុចរិតផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ច ស្របតាមវិសាលភាពនៃតួនាទីនិងភារកិច្ចរបស់បញ្ញត្តិករនោះ ដោយមានការឯកភាពពីគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដើម្បីការពារសិទ្ធិស្របច្បាប់និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

## ជំពូកទី៦

## ព័ត៌មានសម្រាប់អ្នកប្រើប្រាស់

**មាត្រា២៣ .-បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវលាតត្រដាងព័ត៌មានអប្បបរមាដល់អ្នកប្រើប្រាស់ ស្របតាមបទដ្ឋានព័ត៌មានដែលត្រូវកំណត់ដោយប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ចនិងអាចមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ក្នុងករណីចាំបាច់។

**មាត្រា២៤ .- កាតព្វកិច្ចក្នុងការប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បុគ្គលដែលធ្វើធុរកិច្ច ផ្គត់ផ្គង់ សន្យាផ្គត់ផ្គង់ ឬផ្សាយពាណិជ្ជកម្មថានឹងផ្គត់ផ្គង់ទំនិញឬសេវាត្រូវប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

**មាត្រា២៥ .- ការជូនដំណឹងអំពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ត្រូវផ្សព្វផ្សាយដោយបញ្ញត្តិករពាក់ព័ន្ធនិង/ឬគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ហើយនៅពេលដែលត្រូវបានផ្សព្វផ្សាយរួច បទដ្ឋានព័ត៌មាននោះនឹងត្រូវក្លាយជាផ្នែកមួយនៃបទដ្ឋានព័ត៌មានដែលស្ថិតក្រោមច្បាប់នេះ ហើយនឹងត្រូវអនុវត្តដោយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា២៦ .- ការរៀបចំនិងការដាក់ឱ្យអនុវត្តបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បញ្ញត្តិករមានសមត្ថកិច្ចត្រូវរៀបចំបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ដែលទាក់ទងនឹងទំនិញ ឬសេវាសម្រាប់សកម្មភាពធុរកិច្ចដែលស្ថិតក្នុងវិសាលភាពនៃតួនាទីនិងភារកិច្ចរបស់បញ្ញត្តិករទាំងនោះ ដើម្បីការពារសិទ្ធិស្របច្បាប់និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ក្នុងករណីដែលបទប្បញ្ញត្តិរៀបចំដោយបញ្ញត្តិករមានសមត្ថកិច្ចណាមួយ មានទំនាស់នឹងបទប្បញ្ញត្តិដែលរៀបចំដោយបញ្ញត្តិករផ្សេងទៀត គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវពិនិត្យនិងរកវិធីដោះស្រាយ។ ក្នុងករណីមិនអាចដោះស្រាយបាន គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវដាក់សំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា២៧ .- គំរូខ្លឹមសារនៃបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

១- បទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់អាចៈ

ក- លាតត្រដាងព័ត៌មានដែលទាក់ទងនឹងប្រភេទ ចំណាត់ថ្នាក់ សុវត្ថិភាព បរិមាណ ប្រភពដើម មុខងារប្រើប្រាស់ ការថែទាំ សមាសធាតុផ្សំ ការរចនា ការដំឡើង វិធីប្រើ ថ្លៃ ការវេចខ្ចប់ ការផ្សព្វផ្សាយ ឬការផ្គត់ផ្គង់ កាលបរិច្ឆេទផលិត និងកាលបរិច្ឆេទផុតកំណត់ការប្រើប្រាស់ ព័ត៌មានអំពីការផលិត ឬព័ត៌មានដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវា និង/ឬ

ខ- បញ្ជាក់អំពីវិធីដែលព័ត៌មាននេះត្រូវបានទទួល និង/ឬ

គ- បញ្ជាក់អំពីទម្រង់និងរបៀបដែលព័ត៌មាននោះត្រូវបានធ្វើការផ្សព្វផ្សាយទាក់ទងនឹងៈ

- ការផ្គត់ផ្គង់ទំនិញឬសេវា ឬ
- ការផ្គត់ផ្គង់ឡើងវិញឬលទ្ធភាពនៃការផ្គត់ផ្គង់ឡើងវិញនៃទំនិញឬសេវា ឬ
- ការជំរុញផ្សព្វផ្សាយតាមវិធីណាក៏ដោយអំពីចំណុចមួយឬច្រើនពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ការផ្គត់ផ្គង់ឡើងវិញ ឬលទ្ធភាពនៃការផ្គត់ផ្គង់ឡើងវិញ ចំពោះទំនិញឬសេវា ឬ

ឃ- កំណត់បទដ្ឋានព័ត៌មានអប្បបរមាសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅព្រះរាជាណាចក្រកម្ពុជា។

២- រាល់ព័ត៌មានដែលសរសេរត្រូវមានភាសាខ្មែរ តាមប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ច។

៣- គំរូសម្រាប់រៀបចំបទដ្ឋានព័ត៌មានផ្សេងទៀតសម្រាប់ផ្តល់ជូនអ្នកប្រើប្រាស់ អាចត្រូវបានកំណត់ដោយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

## ជំពូកទី៧
## នីតិវិធីនៃការប្តឹងនិងការស៊ើបអង្កេត

**មាត្រា២៨ .- ស្ថាប័នទទួលពាក្យបណ្តឹងនិងស៊ើបអង្កេត**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានសមត្ថកិច្ចទទួលពាក្យបណ្តឹងនិងស៊ើបអង្កេតតាមរយៈ៖

១- ការផ្តួចផ្តើមរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ខ្លួនឯង ឬ

២- បណ្តឹងពីបុគ្គលណាមួយឬសមាគមអ្នកប្រើប្រាស់ណាមួយ

៣- បណ្តឹងពីបញ្ញត្តិករមានសមត្ថកិច្ចណាមួយ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចស្នើសុំកិច្ចសហការពីស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចដើម្បីបំពេញភារកិច្ចខាងលើ ហើយស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចនោះត្រូវផ្តល់កិច្ចសហការតាមការស្នើសុំរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា២៩ .- ការតែងតាំងមន្ត្រីស៊ើបអង្កេត**

មន្ត្រីស៊ើបអង្កេតត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីស៊ើបអង្កេត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣០ .- សិទ្ធិអំណាចត្រួតពិនិត្យ**

មន្ត្រីស៊ើបអង្កេតមានសិទ្ធិដូចតទៅៈ

១- អង្កេត ស្រាវជ្រាវ និងប្រមូលភស្តុតាងពាក់ព័ន្ធនឹងការបំពានច្បាប់នេះ។

២- ត្រួតពិនិត្យផលិតផល ទំនិញនិងសេវា ការផ្សព្វផ្សាយពាណិជ្ជកម្មលក់ ការលក់ផលិតផលណាមួយ ឬការស្តុកទុកចែកចាយដែលតម្រូវឱ្យមានភាពអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

៣- យកសំណាកផលិតផលឬឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត ក្នុងករណីមានការសង្ស័យថាមានការបំពានច្បាប់នេះ។

៤- សាកសួរបុគ្គលពាក់ព័ន្ធដើម្បីទទួលចម្លើយឬឱ្យបញ្ជូនឯកសារឬវត្ថុផ្សេងៗដើម្បីធ្វើការពិចារណា។

៥- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្គត់ផ្គង់ ការចែកចាយ ឬចរាចរណ៍លើទីផ្សារនូវប្រភេទផលិតផល ទំនិញ ឬសេវាទាំងឡាយណាដែលបានស្រាវជ្រាវឃើញភស្តុតាងថាមិនមានភាពអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ហើយត្រូវរាយការណ៍ជូនគណៈកម្មការធិការជាតិការពារអ្នកប្រើប្រាស់ដើម្បីសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ សហការចាត់វិធានការបន្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣១ .- សិទ្ធិអំណាចចុះឆែកឆេរ**

មន្ត្រីស៊ើបអង្កេតត្រូវបានអនុញ្ញាតឱ្យចុះដល់ទីកន្លែងនិងឆែកឆេរទីកន្លែងណាមួយដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីស៊ើបអង្កេតដែលត្រូវចុះបំពេញភារកិច្ចក្នុងបរិវេណ ទីតាំង មានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ និងត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៨
## នីតិវិធីនៃការចេញសេចក្តីសម្រេច

**មាត្រា៣២ .- នីតិវិធីនៃការចេញសេចក្តីសម្រេច**

បន្ទាប់ពីការស៊ើបអង្កេត គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានអំណាចតាមច្បាប់នេះលើការៈ

១- ចេញសេចក្តីសម្រេច និង/ឬ

២- ចេញការកំណត់ទណ្ឌកម្មរដ្ឋបាល

ក្នុងការចេញសេចក្ដីសម្រេចនិង/ឬការកំណត់ទណ្ឌកម្មរដ្ឋបាល គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចធ្វើការពិចារណាលើចំណាត់ការនានាឬលើសំណូមពរដែលបានស្នើឡើងដោយបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធ ទាក់ទងនឹងការអនុម័តយល់ព្រម ការកែតម្រូវ ឬការបដិសេធចំណាត់ការចំពោះសំណូមពរដែលស្នើឡើងនោះ។

**មាត្រា៣៣.- នីតិវិធីនៃការដោះស្រាយ**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចធ្វើការដោះស្រាយតាមការចរចាជាមួយបុគ្គលដែលបានបំពានបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ។

រាល់ការដោះស្រាយមិនត្រូវអនុវត្តលើ៖

១- ករណីព្រហ្មទណ្ឌ។

២- ការបំពានបទប្បញ្ញត្តិនានានៃច្បាប់នេះជាថ្មីទៀតរបស់បុគ្គលនោះទៀយ។

នីតិវិធីនៃការដោះស្រាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣៤.- សេចក្ដីសម្រេចឱ្យបង្ហាញព័ត៌មានឬផ្សព្វផ្សាយឡើងវិញ**

នៅពេលដែលគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់រកឃើញថាបុគ្គលណាមួយដែលពាក់ព័ន្ធបានបំពាននឹងបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចចេញបទបញ្ជាដូចខាងក្រោម៖

១- តម្រូវឱ្យបុគ្គលដែលមិនបានផ្សព្វផ្សាយព័ត៌មានឬផ្សព្វផ្សាយព័ត៌មានមិនគ្រប់គ្រាន់ធ្វើការផ្សព្វផ្សាយព័ត៌មាននោះឬចំណុចណាមួយនៃព័ត៌មាននោះឱ្យបានគ្រប់គ្រាន់ តាមវិធីដូចដែលបានបញ្ជាក់ក្នុងបទបញ្ជា ដោយចំណាយថវិកាផ្ទាល់ខ្លួនជូនសាធារណជនឬបុគ្គលពាក់ព័ន្ធណាមួយ។

២- តម្រូវឱ្យបុគ្គលដែលបានផ្សព្វផ្សាយព័ត៌មានខុសឬបំភាន់នោះ ធ្វើសេចក្ដីកែតម្រូវឡើងវិញតាមវិធីដូចដែលបានបញ្ជាក់ក្នុងបទបញ្ជា ដោយចំណាយថវិកាផ្ទាល់ខ្លួន។

**មាត្រា៣៥.- សេចក្ដីសម្រេចហាមឃាត់ពីមុខងារគ្រប់គ្រង**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចចេញសេចក្ដីសម្រេចហាមឃាត់បុគ្គលណាមួយពីមុខងារគ្រប់គ្រងបាន ប្រសិនបើ៖

១- បុគ្គលនោះបានប្រព្រឹត្តល្មើសដូចខាងក្រោមចាប់ពី២(ពីរ)ដងឡើងទៅ៖

- អំពើមិនសុចរិតពាក់ព័ន្ធនឹងទំនិញនិង/ឬសេវា
- ការអះអាងដោយបំភាន់
- ការសន្យាផ្ដល់ជាអំណោយនិងរង្វាន់
- ការផ្សាយពាណិជ្ជកម្មជានុយ
- ការលក់អូសទាញដោយមិនសុចរិត
- ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ
- ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន
- ការបង្ខិតបង្ខំដោយកម្លាំងនិងការគំរាមតាមផ្លូវចិត្ត
- គម្រោងលក់បែបពីរ៉ាមីដ និង
- ការលក់ទំនិញដែលមានភ្ជាប់សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិត។

២- បុគ្គលនោះបានប្រព្រឹត្តល្មើសដូចខាងក្រោម យ៉ាងតិច២(ពីរ)ដង ក្នុងរយៈពេល៥(ប្រាំ) ឆ្នាំ នៅពេលដែលបុគ្គលនោះមានឋានៈជានាយក ឬអ្នកគ្រប់គ្រងរបស់នីតិបុគ្គលៈ

- មិនបានលាតត្រដាងបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់
- មិនបានបំពេញកាតព្វកិច្ចក្នុងការប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់
- មិនបានធ្វើការជូនដំណឹងអំពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

៣- បុគ្គលដែលត្រូវបានហាមឃាត់ដោយរដ្ឋបរទេសទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ ដូចមានចែងក្នុងចំណុច១និង២។

**មាត្រា៣៦.- ការផ្សព្វផ្សាយសេចក្ដីសម្រេចហាមឃាត់ពីមុខងារគ្រប់គ្រង**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវផ្ដល់ច្បាប់ចម្លងសេចក្ដីសម្រេចហាមឃាត់នីមួយៗ ដែលមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ ឱ្យទៅៈ

ក- បុគ្គលពាក់ព័ន្ធឬសមាគមអ្នកប្រើប្រាស់ណាមួយ។

ខ- បញ្ញត្តិករមានសមត្ថកិច្ច និង

គ- អង្គភាពចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចហាមឃាត់នានា ដែលមានចែងនៅក្នុងមាត្រា៣៥នៃច្បាប់នេះ នៅលើគេហទំព័រឬព្រឹត្តិបត្ររបស់ខ្លួនឬតាមមធ្យោបាយផ្សេងទៀត ។

**មាត្រា៣៧.- រយៈពេលនៃការហាមឃាត់ពីមុខងារគ្រប់គ្រង**

ការហាមឃាត់មិនឱ្យកាន់តួនាទីជានាយកឬជាអ្នកគ្រប់គ្រងរបស់នីតិបុគ្គលក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវតិចជាង២(ពីរ)ឆ្នាំនិងមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំឡើយ។

## ជំពូកទី៩
## ការប្ដឹងតវ៉ា

**មាត្រា៣៨.- ការកែតម្រូវលើសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

បុគ្គលណាមួយដែលពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ អាចប្ដឹងទាមទារឱ្យគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ពិនិត្យឡើងវិញ កែតម្រូវ ឬដកសេចក្ដីសម្រេច ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលសេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេច។

បណ្ដឹងឱ្យពិនិត្យឡើងវិញ ត្រូវបញ្ជាក់ចំណុចដូចខាងក្រោមៈ

- បញ្ជាក់ឱ្យបានច្បាស់ថាការរកឃើញណាមួយឬច្រើនរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចតវ៉ាបាន និង
- បង្ហាញថាសេចក្ដីសម្រេច ឬទណ្ឌកម្មរដ្ឋបាលរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ មិនមានភស្តុតាងរឹងមាំដូចបានបញ្ជាក់នៅក្នុងកំណត់ហេតុរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

ក្នុងករណីនេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវពិនិត្យនិងសម្រេចក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃយ៉ាងយូរ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៣៩ .- សិទ្ធិក្នុងការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច**

បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ អាចប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបាន ក្នុងរយៈពេល៣០(សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចុងក្រោយ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា៤០ .- ទណ្ឌកម្មនិងការពិន័យអន្តរការណ៍**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេត។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីស៊ើបអង្កេតអាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤១ .- អំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនសុចរិតពាក់ព័ន្ធនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដូចមានចែងក្នុងមាត្រា៩ មាត្រា១០ មាត្រា១១ និងមាត្រា១២។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសតាមកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរ ដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ។

ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១ខាងលើនេះ ពាក់ព័ន្ធនឹងគុណភាពនិងប្រភពដើមនៃទំនិញ។

**មាត្រា៤២ .- ស្ថានទម្ងន់ទោសនៃអំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដោយសារប៉ះពាល់ដល់សុខភាពនិងសុវត្ថិភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១នៃមាត្រា៤១ ក្នុងករណីដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់។

**មាត្រា៤៣ .- ស្ថានទម្ងន់ទោសនៃអំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដោយសារពិការភាពឬមរណភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១នៃមាត្រា៤១ ដែលបណ្តាលឱ្យមានពិការភាពអចិន្ត្រៃយ៍ឬបណ្តាលឱ្យបាត់បង់អាយុជីវិត។

**មាត្រា៤៤ .- អំពើទាក់ទងនឹងការអនុវត្តមិនសុចរិត**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តការផ្សាយពាណិជ្ជកម្មជានុយ ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន ការបង្ខិតបង្ខំដោយកម្លាំង និងការគំរាមតាមផ្លូវចិត្ត។

**មាត្រា៤៥ .- អំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត។

**មាត្រា៤៦ .- ស្ថានទម្ងន់ទោសនៃការលក់បែបពីរ៉ាមីដឬលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដោយសារប៉ះពាល់ដល់សុខភាពនិងសុវត្ថិភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ហើយដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់។

**មាត្រា៤៧ .- ស្ថានទម្ងន់ទោសនៃការលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដោយសារពិការភាពឬមរណភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដែលបណ្តាលឱ្យមានពិការភាពអចិន្ត្រៃយ៍ឬបណ្តាលឱ្យបាត់បង់អាយុជីវិត។

**មាត្រា៤៨ .- អំពើល្មើសលើការមិនអនុលោមតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនអនុលោមតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

**មាត្រា៤៩ .- អំពើបំពានសេចក្តីសម្រេចដែលហាមឃាត់ពីការគ្រប់គ្រង**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលណាដែលបំពានសេចក្តីសម្រេចដែលហាមឃាត់ពីការគ្រប់គ្រង។

ROYAUME DU CAMBODGE
LE CABINET DU PALAIS

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៥០ .-** ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៥១ .-** ប្រកាសជាការប្រញាប់

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

ពារស.១៩១១.១៦៥៣

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្ដិ**